01298903

D191/6

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស |
| ដាក់ជូន: | ការិយាល័យសហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ |
| ភាគីដាក់ឯកសារ: | អ្នកមិនមែនជាភាគីនៃរឿងក្តី (Robinson, deGuzman, Jalloh, Cryer) |
| ភាសាដើម: | អង់គ្លេស (ឯកសារដើម) |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |
| ទំព័រ: | ៩ (រួមទាំង ក្របទំព័រ) |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:36
CMS/CFO: Sann Rada

---

**សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី សាស្ត្រាចារ្យ** Robinson, deGuzman, Jalloh **និង** Cryer **ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សំណុំរឿង ០០៣ និង ០០៤)**

---

**ដាក់ដោយ៖**

Darryl ROBINSON

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael G. KARNAVAS

**ការិយាល័យរដ្ឋបាល**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ហុង គីមសួន

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

សំ សុគង់

ទី ស្រីនណា

វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

## សេចក្ដីផ្ដើម

### *សាវតារនីតិវិធី*

1. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander បានអញ្ជើញឱ្យអ្នកសិក្សាស្រាវជ្រាវច្បាប់ព្រហ្មទណ្ឌអន្តរជាតិដាក់សេចក្ដីសន្និដ្ឋានស្ដីពីការបកស្រាយ "ជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាពិសេស នៅក្នុងបរិបទនៃការវាយប្រហារលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋខ្លួនឯង[1]។ អាស្រ័យហេតុនេះ សាស្ត្រាចារ្យ Darryl Robinson សាស្ត្រាចារ្យ Margaret deGuzman សាស្ត្រាចារ្យ Charles Jalloh និងសាស្ត្រាចារ្យ Robert Cryer (ចាប់ពីពេលនេះទៅហៅកាត់ថា "អ្នកមិនមែនជាភាគីនៃរឿងក្ដី") សូមដាក់សារណានេះ។ អ្នកមិនមែនជាភាគីនៃរឿងក្ដីគឺជាសាស្ត្រាចារ្យចំនួនបួនរូបដែលមានជំនាញក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយជាពិសេសលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[2]។ អ្នកមិនមែនជាភាគីនៃរឿងក្ដីធ្លាប់បានដាក់សេចក្ដីសង្កេតក្នុងនាមជា*អ្នកមិនមែនជាភាគីនៃរឿងក្ដី*ចមកហើយលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជូនទៅអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ[3]។

### *ទិដ្ឋភាពសង្ខេប*

2. យើងឃើញមានទស្សនៈចំនួនពីរលើការបកស្រាយ "ជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ទស្សនៈមួយនោះអាចហៅថា ទស្សនៈ "ផ្អែកលើឋានៈ" ដែលមិនរួមបញ្ចូលគ្រប់សមាជិកនៃកងកម្លាំងប្រដាប់អាវុធណាមួយនោះទេ។ ទស្សនៈមួយទៀតអាចហៅថា ទស្សនៈ "ផ្អែកលើគោលដៅស្របច្បាប់" ដែលមិនរួមបញ្ចូលការវាយប្រហារប្រឆាំងនឹងគោលដៅស្របច្បាប់នោះទេ ពោលគឺ ជនចូលរួមប្រយុទ្ធនៃភាគីសត្រូវនៅក្នុងជម្លោះ។ ទស្សនៈ "ផ្អែកលើគោលដៅស្របច្បាប់" ឆ្លុះបញ្ចាំងយ៉ាងសមស្របអំពីគោលការណ៍នៃការបែងចែក ការធ្វើសុខដុមរមនីយកម្មលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាមួយនឹងច្បាប់មនុស្សធម៌ ហើយវាស៊ីសង្វាក់ជាមួយនឹងយុត្តិសាស្ត្រនានារួមទាំងរឿងក្ដីក្រោយសង្គ្រាមលោកលើកទីពីរផងដែរ។ ទស្សនៈ "ផ្អែកលើឋានៈ" លេចចេញនៅក្នុងរឿងក្ដីដែលមានហេតុផលចង្អៀត ខ្វះហេតុផល និងបង្កបញ្ហានូវផលប៉ះពាល់។

---

[1] *"សេចក្ដីអំពាវនាវឱ្យដាក់សេចក្ដីសន្និដ្ឋានដោយភាគីនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ និងសេចក្ដីអំពាវនាវឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី"* ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦។

[2] *សូមមើល ឧបសម្ព័ន្ធ (គុណវុឌ្ឍិរបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី*។

[3] ICC Doc. ICC-02/11-01/11-516 *ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៣ (អង្គជំនុំជម្រះតុលាការកំពូល)* ។ ICC Doc. ICC-02/11-01/11-534 *ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ (សេចក្ដីសង្កេតរបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី)* ។

ផលប៉ះពាល់មួយគឺអំពើហិង្សា ឬ ការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសមាជិកនៃកងទ័ពរបស់រដ្ឋខ្លួនឯង នឹងជាទូទៅមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម (ដោយសារពួកគេពុំមែនជាភាគីបដិបក្ខ) ហើយក៏មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ។ ដូច្នេះ វានឹងការជាការដកហូតតាមទំនើងចិត្តនូវការការពារតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិដោយសារការកាន់កាប់របស់ពួកគេ។ ទោះបីជារឿងក្ដីមុនៗនៃសាលាក្ដី ICTY បានយកតាម ទស្សនៈបុរាណ "ផ្អែកលើគោលដៅស្របច្បាប់" ក៏ដោយ រឿងក្ដីថ្មីៗនៃសាលាក្ដី ICTY បានងាកចេញពីទស្សនៈនេះដោយពុំបានវិភាគឲ្យបានសមស្រប។ អ្នកមិនមែនជាភាគីនៃរឿងក្ដីសូមជម្រុញឲ្យ អ.វ.ត.ក គោរពតាមទស្សនៈស្ដីពីខុសគ្នារវាងជនស៊ីវិល និងអ្នកប្រយុទ្ធ (ពោលគឺ គោលដៅស្របច្បាប់)។

**<u>សេចក្ដីសន្និដ្ឋាន</u>**

3. ចំពោះការបកស្រាយលើ "ប្រជាជនស៊ីវិល" ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចរួមបញ្ចូលទាំងឧក្រិដ្ឋកម្មជាយថាហេតុប្រឆាំងនឹងបុគ្គលិកយោធាផងដែរដរាបណាពួកគេគឺជាផ្នែកនៃការវាយប្រហារដ៏ធំធេងមួយ[4]។ ក៏ប៉ុន្តែ វាមានបញ្ហាបឋមសំខាន់មួយនៃអត្ថន័យ និងវិសាលភាពនៃលក្ខខណ្ឌតម្រូវនៃ "ជនស៊ីវិល"។ តើការវាយប្រហារជាលក្ខណៈទូទៅ ឬ ជាលក្ខណៈប្រព័ន្ធលើសមាជិកបច្ចុប្បន្ន និងអតីតបុគ្គលិកនៃកងកម្លាំងប្រដាប់អាវុធ (ឧ. ឈ្លើយសឹកសង្គ្រាម ឬសមាជិកយោធាដូចគ្នា) អាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដោយផ្ទាល់តែម្ដងដែរឬទេ? យោងតាមវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់" ដ៏ត្រឹមត្រូវ "ជនស៊ីវិល" ត្រូវបានបកស្រាយស្របតាមគោលការណ៍នៃការបែងចែក។ ការវាយប្រហារបែបនេះពុំអាចធ្វើឡើងត្រឹមត្រូវតាមច្បាប់ ហើយអាចចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាន។

**ក. ហេតុផលនៃលក្ខខណ្ឌតម្រូវនៃ "ជនស៊ីវិល" គឺមិនត្រូវដាក់បញ្ចូលការវាយប្រហារស្របច្បាប់លើគោលដៅយោធានោះទេ**

4. ច្បាប់អន្តរជាតិអនុញ្ញាតឲ្យមានការវាយប្រហារជាលក្ខណៈទូទៅ និងជាលក្ខណៈប្រព័ន្ធប្រឆាំងនឹងអ្នកប្រយុទ្ធជាគូសត្រូវបានប្រសិនបើការប្រព្រឹត្តទាំងនេះធ្វើឡើងក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ និងស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ។ ដូច្នេះ ចំណុចយោងលើ ""ជនស៊ីវិល" មានគោលបំណងបញ្ជាក់នូវមុខងារដែលមិនត្រូវរួមបញ្ចូលសកម្មភាពយោធាប្រឆាំងនឹងគោលដៅយោធាស្របច្បាប់នោះទេអនុលោមតាមច្បាប់មនុស្សធម៌អន្តរជាតិ"[5]។

---

[4] *សូមមើល ឧ. រឿងក្ដី Martic* IT-95-11-A *សាលដីកា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ៣១៣។*

[5] Cryer *និងអ្នកផ្សេងទៀត An Introduction to International Criminal Law and Procedure* 3d ed. (Cambridge 2014) *ទំព័រ ២៤១។*

5. ការយល់អំពីពាក្យ "ជនស៊ីវិល" ឃើញកើតមានជាយូរមកហើយនៅក្នុងយុត្តិសាស្ត្រ។ ពាក្យ "ជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានយល់ឃើញផ្ទុយពីគោលដៅយោធាស្របច្បាប់ អនុលោមតាមគោលការណ៍នៃការបែងចែក[6] ពោលគឺ អ្នកប្រយុទ្ធរបស់គូសត្រូវ។ ដូច្នេះ Yoram Dinstein ដែលបាននិពន្ធសៀវភៅនៅក្នុងឆ្នាំ២០០០ បានសរសេរថា ពាក្យ "ជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ពុំចាំបាច់លើកឡើងនូវបញ្ហាចោទជាច្រើនពេកនោះទេ" ដោយហេតុថាពាក្យនេះត្រូវបានគេចាត់ទុកតាំងពីបុរាណ និងស្របគ្នាថាជាពាក្យផ្ទុយនឹងអ្នកប្រយុទ្ធ[7]។

6. Kai Ambos និង Steffen Wirth សង្ខេបយ៉ាងត្រឹមត្រូវនូវយុត្តិសាស្ត្រដែលឃើញមានជាយូរណាស់មកហើយលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចខាងក្រោម៖

> **ជនស៊ីវិលគឺជាជនដែលពុំមែនជាសមាជិកសកម្មនៃកងកម្លាំងប្រដាប់អាវុធរបស់គូសត្រូវ** ឬ ជាអ្នកប្រយុទ្ធដែលបានដាក់អាវុធចុះ ឬ ត្រូវបានចាត់ទុកជាអ្នកបោះបង់ចោលការប្រយុទ្ធ។ ឋានៈផ្លូវការរបស់ជនរងគ្រោះក្នុងនាមជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធម្នាក់ មិនថា របស់គូសត្រូវ ឬ មែនមែនក៏ដោយ ពុំមានការជាប់ពាក់ព័ន្ធនោះឡើយ"[8]។

7. ស្រដៀងគ្នានេះដែរ Gerhard Werle និង Florian Jessberger ក៏បានសន្និដ្ឋានផងដែរថា "អ្វីដែលសំខាន់នោះគឺ *មិនមែនឋានៈផ្លូវការនោះទេ* ដូចជាសមាជិកភាពនៅក្នុងអង្គភាព ឬ កងកម្លាំងយោធាជាក់លាក់ ប៉ុន្តែ*តួនាទីជាក់លាក់*របស់ជនណាម្នាក់នៅក្នុងអំឡុងពេលនៃឧក្រិដ្ឋកម្ម"[9]។ ដូច្នេះ "ជនស៊ីវិល" រួមទាំងអ្នកប្រយុទ្ធដែលបានដាក់អាវុធចុះ ឬ គឺជាអ្នកបោះបង់ចោលការប្រយុទ្ធ ឬ គឺជាឈ្លើយសឹក[10]។

8. ការយល់លើពាក្យ "ជនស៊ីវិល" (ទស្សនៈ "ផ្អែកលើគោលដៅស្របច្បាប់") បំពេញគោលបំណងនៃលក្ខខណ្ឌតម្រូវនេះ ចុះបញ្ជាំងគោលការណ៍នៃការបែងចែក ជៀសវៀងវិវាទរវាងច្បាប់ស្ដីពី

---

[6] ចំពោះគោលការណ៍នៃការបែងចែករវាងអ្នកប្រយុទ្ធ និងអ្នកមិនប្រយុទ្ធថាជា "គោលការណ៍មូលដ្ឋាន" សូមមើល *Legality of the Threat or Use Nuclear Weapons* ICJ Reports 1996 កថាខណ្ឌ ៧៨។

[7] Dinstein "Crimes Against Humanity After Tadic" 13 LJIJ (2000) 373 ត្រង់ ៣៨៨។

[8] Ambos & Wirth "The Current Law of Crimes Against Humanity: An Analysis of UNTAET Regulation 15/2000" (2002) 13 Crim. L. Forum 1 ត្រង់ ៨៥។ សូមមើលផងដែរដូចខាងលើត្រង់ ២៥-២៦៖ "ដូច្នេះ សរុបមក គ្រប់ជនទាំងអស់មិនថាមានឋានៈផ្លូវការជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធឬមិនមែនទេនោះត្រូវចាត់ទុកថាជាជនស៊ីវិលលើកលែងតែកងកម្លាំងទាំងនោះជាគូសត្រូវចំពោះចារី និងជនដែលពុំបានដាក់អាវុធចុះ ឬ ត្រូវបានចាត់ទុកជាអ្នកបោះបង់ចោលការប្រយុទ្ធ"។

[9] Werle & Jessberger *Principles of International Criminal Law,* 3rd ed. (Oxford 2014) ទំព័រ ៣៣៥ (គូសបញ្ជាក់បន្ថែម)។

[10] *ដូចខាងលើ*។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាមួយនឹងច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម និងអនុវត្តស្របតាមយុត្តិសាស្ត្រមុនៗ។

**ខ. យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរឆ្លុះបញ្ចាំងវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់"**

9. ដូច Ambos និង Wirth បានកត់សម្គាល់ ការបកស្រាយ "ទូលាយ" លើជនស៊ីវិល (វិធីសាស្ត្រផ្អែកលើគោលដៅស្របច្បាប់)[11]គឺ "មានការគាំទ្រខ្លាំងពីច្បាប់យុត្តិសាស្ត្រគិតចាប់ពីសេចក្តីសម្រេចរបស់តុលាការអាល្លឺម៉ង់អនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០"៖

> នៅក្នុងរឿងក្តីនៃតុលាការកំពូលអាល្លឺម៉ង់ក្នុងទឹកដីកាន់កាប់ដោយចក្រភពអង់គ្លេស ចុងចោទត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពចំពោះអំពើកាត់ទោសប្រហារជីវិត និងអំពើបញ្ជាឲ្យកាប់សម្លាប់ទាហាន (អាល្លឺម៉ង់) ចំនួនពីររូបដែលបានរត់ចោលជួរនៅប៉ុន្មានថ្ងៃចុងក្រោយនៃសង្គ្រាម។ តុលាការនេះបានកត់សម្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងទាហានទាំងពីរនេះមិនត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិលនោះទេ ក៏ប៉ុន្តែតុលាការនេះបានសម្រេចថា ករណីនេះមិនមានសារសំខាន់នោះទេដោយសារឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងទាហានផងដែរ។ នៅក្នុងរឿងក្តីមួយទៀត តុលាការដដែលបានសម្រេចឲ្យចុងចោទមានពិរុទ្ធភាពចំពោះអំពើកាត់ទោសប្រហារជីវិតទាហាន (អាល្លឺម៉ង់) ចំនួនពីររូបដែលបានប្រព្រឹត្ត "ឧក្រិដ្ឋកម្ម" នៃការបំបាក់ស្មារតីកងកម្លាំងប្រដាប់អាវុធ (Wehrkraftzersetzung)។ សេចក្តីសម្រេចទាំងពីរនេះគាំទ្រទស្សនៈដែលថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងទាហាននៃពលរដ្ឋតែមួយដែលជាចារី[12]។

10. ស្រដៀងគ្នានេះដែរ Antonio Cassese បានពិនិត្យមើលឡើងវិញលើរឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរដោយបានសន្និដ្ឋានថា ទោះបីជារឿងក្តីមួយចំនួនអនុវត្តតាមវិធីសាស្ត្រ "ផ្អែកលើឋានៈ" ក៏ដោយ រឿងក្តីភាគច្រើនយកតាមវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់"។ ជាពិសេស រឿងក្តីពាក់ព័ន្ធនានាដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយពលរដ្ឋអាល្លឺម៉ង់ប្រឆាំង

---

[11] Ambos & Wirth *ទំព័រ ៨៥*។

[12] ដូចខាងលើ ទំព័រ ២៣ ដែលពិភាក្សារឿងក្តីលេខ StS 111/48 សាលក្រម ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៨ (តុលាការកំពូលអាល្លឺម៉ង់នៅក្នុងទឹកដីកាន់កាប់ដោយចក្រភពអង់គ្លេស) 1 Entscheidungen des Obersten Gerichtshofes der Britischen Zone in Strafsachen 219 ត្រង់ ២២៨។ រឿងក្តីលេខ StS 309/49, 18.10។ 2 Entscheidungen des Obersten Gerichtshofes der Britischen Zone in Strafsachen 231។

នឹងទាហាន និងមន្ត្រីអាល្លឺម៉ង់ ដូចជា ការចោលទោសពួកគេ ឬ ការកាប់សម្លាប់ពួកគេដោយសារការប៉ុនប៉ងរត់គេច ឬ ដោយសារវិះគន់របបនោះ[13]។

11. Henri Meyrowitz ក្រោយពីបានពិនិត្យមើលឡើងវិញលើរឿងក្ដីក្នុងសម័យសង្គ្រាមលោកលើកទីពីរបានសន្និដ្ឋានថា៖

[redacted]

12. រឿងក្ដីមួយចំនួននៅក្នុងសម័យសង្គ្រាមលោកលើកទីពីរចាត់ទុកឧក្រិដ្ឋកម្មធំៗប្រឆាំងនឹងឈ្លើយសឹកដោយប្រយោលថាជាឧក្រិដ្ឋកម្មកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងនៅក្នុងប្រទេសអាល្លឺម៉ង់[15] និងប្រទេសជប៉ុន[16]។

---

[13] Cassese *និងអ្នកផ្សេងទៀត Cassese's International Criminal Law* 3rd ed. (Oxford, 2013) *ទំព័រ ១០១-១០៣។*

[14] *ការបកប្រែក្រៅផ្លូវការ។* Henri Meyrowitz *La'répression par les tribunaux allemands des crimes contre l'humanité et de l'appartenance a une organization criminelle en application de la loi n° 10 du Conseil de Contrôle Allié* ទំព័រ ២៨២។

[15] *រឿងក្ដី សហរដ្ឋអាមេរិក ទល់នឹង Greifeldt និងអ្នកផ្សេងទៀត* ("*រឿងក្ដី* RuSHA") *ការជំនុំជម្រះចំនួនប្រាំករណីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្ដីយោធានូរ៉ឹមប៊ឺកត្រង់ ៨៨។ រឿងក្ដី សហរដ្ឋអាមេរិក ទល់នឹង Hermann Göring និងអ្នកផ្សេងទៀត ការជំនុំជម្រះចំនួនមួយករណីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្ដីយោធាអន្តរជាតិ ១៧១ ទំព័រ ២៩២ សំដៅលើ "កម្មវិធីក្នុងលក្ខណៈទូទៅនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឧក្រិដ្ឋកម្មទាំងនេះរួមទាំងការធ្វើមនុស្សឃាត និងការធ្វើបាបឈ្លើយសឹក"។ រឿងក្ដី Milch បានពិចារណាឧក្រិដ្ឋកម្មប្រឆាំងនឹងឈ្លើយសឹក (ទំព័រ ៧៧៩) ថាជាឧក្រិដ្ឋកម្មសង្គ្រាម (ទំព័រ៧៩០) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ទំព័រ ៧៩១)។ រឿងក្ដី សហរដ្ឋអាមេរិក ទល់នឹង Milch* ("*រឿងក្ដី* Milch") *ការជំនុំជម្រះចំនួនពីរករណីលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្ដីយោធានូរ៉ឹមប៊ឺក* (TWCNMT) *ត្រង់ ៧៧៣។ រឿងក្ដី Justic បានចាត់ទុកឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិកចលនាតស៊ូ* ("*ក្រឹត្យច្បាប់* Night and Fog") *ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (១០៣២, ១០៥៥-៥៧)។ រឿងក្ដី សហរដ្ឋអាមេរិក ទល់នឹង Altstoetter និងអ្នកផ្សេងទៀត* ("*រឿងក្ដី Justice*") *៣* TWCNMT *ត្រង់ ៩៥៤។*

[16] *ដកស្រង់ចេញពីការជំនុំជម្រះនៃ* Takashi Sakai *រឿងក្ដីលេខ ៨៣ របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ត្រង់ ៧។*

13. យុត្តិសាស្ត្រជាតិផ្សេងៗទៀតឃើញលេចចេញនូវលទ្ធផលស្រដៀងគ្នា។ នៅក្នុងរឿងក្តី *Barbie* (ប្រទេសបារាំង) តុលាការកំពូលបានច្រានចោលសាលក្រមរបស់តុលាការជាន់ទាបដែលបានអនុវត្តតាមវិធីសាស្ត្រ "ផ្អែកលើឋានៈ"។ តុលាការបានសម្រេចថា "វាជាកំហុសក្នុងការដកអំពើទាំងអស់ចេញពីប្រភេទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ...ដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិក ឬ អ្នកដែលអាចជាសមាជិកនៃកងកម្លាំងតស៊ូ"[17]។ រឿងក្តី *Touvier* (ប្រទេសបារាំង) ក៏បានបញ្ជាក់ផងដែរថា សញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអនុវត្តលើឧក្រិដ្ឋកម្មប្រឆាំងនឹងអតីតសមាជិកនៃកងកម្លាំងតស៊ូផងដែរ[18]។

14. ស្ថាប័នអន្តរជាតិក៏បានអនុវត្តតាមវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់" ផងដែរ។ គណកម្មការអ្នកជំនាញស្តីពីអតីតប្រទេសយូហ្គោស្លាវីបានបកស្រាយ "ជនស៊ីវិល" នៅក្នុងមាត្រា ៥ ថា "សំដៅលើជនដែលពុំមែនជាអ្នកប្រយុទ្ធ"។ ទោះបីជាយ៉ាងនេះក៏ដោយ ការបកស្រាយនេះមិនគួរនាំដល់ការសន្និដ្ឋានយ៉ាងលឿនមួយលើជនដែលកាន់អាវុធនៅក្នុងពេលជាក់លាក់ណាមួយនោះឡើយ"[19]។

**គ. យុត្តិសាស្ត្រនៃសាលាក្តី** ICTY/**សាលាក្តី** ICTR **ដំបូងបានអនុវត្តតាមវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់"**

15. យុត្តិសាស្ត្ររបស់សាលាក្តីមិនអចិន្ត្រៃយ៍នានាពីដំបូងក៏បានយកតាមវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់" ផងដែរ។ ឧទាហរណ៍ សាលាក្តី ICTR នៅពេលបកស្រាយឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរឿងក្តី *Akayesu* បានសម្រេចថា៖

> ប្រជាជនស៊ីវិលគឺជាជន**ដែលមិនកំពុងចូលរួមយ៉ាងសកម្មណាមួយ**នៅក្នុងការប្រទូស្តរ៉ាយ **រួមទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានដាក់**អាវុធចុះ និងជនទាំងឡាយដែលបានក្លាយជា**អ្នកបោះបង់ការប្រយុទ្ធ**ដោយសារជំងឺ របួស ការឃុំឃាំង ឬ មូលហេតុផ្សេងទៀត[20]។

---

[17] *ព្រហ្មទណ្ឌ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨៥ ព្រឹត្តិបត្រលេខ ៤០៧ តុលាការកំពូល (សភាព្រហ្មទណ្ឌ) M. Barbie បកប្រែ និងបោះពុម្ពឡើងវិញនៅក្នុង* 78.I.L.R 141 *ត្រង់ ១៤៧*។

[18] *ព្រហ្មទណ្ឌ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩២ ព្រឹត្តិបត្តិលេខ ៣៩៤ តុលាការកំពូល (សភាព្រហ្មទណ្ឌ) M.Touvier បកប្រែ និងបោះពុម្ពឡើងវិញនៅក្នុង* 100.I.L.R 315 *ត្រង់ ៣៥២*។

[19] *របាយការណ៍ចុងក្រោយរបស់គណកម្មការអ្នកជំនាញដែលបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៧៨០ (ឆ្នាំ១៩៩២)* UN Doc S/1994/674 ឧបសម្ព័ន្ធ (ឆ្នាំ១៩៩៤) កថាខណ្ឌ ៧៨។

[20] *រឿងក្តី Akayesu* ICTR-96-4-T *សាលក្រម ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥៨២*។

អង្គជំនុំជម្រះបានកត់សម្គាល់យ៉ាងត្រឹមត្រូវថា "និយមន័យនេះច្របាច់បញ្ចូលនិយមន័យនៃ "ជនស៊ីវិល" ទៅក្នុងប្រភេទនៃជនដែលត្រូវបានការពារដោយមាត្រា ៣ រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ពោលគឺ ការច្របាច់បញ្ចូលគ្នានេះពុំទំនងជាបង្កនូវបញ្ហាអ្វីនោះឡើយ"[21]។

16. នៅក្នុងរឿងក្តី *Tadic* អង្គជំនុំជម្រះ និងភាគីទាំងសងខាងបានយល់ស្របតាម "ជនស៊ីវិល" មានន័យថា "អ្នកមិនចូលរួមប្រយុទ្ធ"[22]។ ដូចនៅក្នុងរឿងក្តី *Akayesu* ដែរ អង្គជំនុំជម្រះបានសម្រេចថា ពាក្យនេះស៊ីសង្វាក់គ្នានឹងនិយមន័យនៅក្នុងមាត្រា ៣ រួម ដែលកំណត់ថា "ជនដែលពុំបានចូលរួមសកម្មនៅក្នុងការប្រទូស្តរ៉ាយ រួមទាំង សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានដាក់អាវុធចុះ ហើយជនដែលត្រូវបានចាត់ទុកថាជាអ្នកបោះបង់ការប្រយុទ្ធ..."[23]។ ដូចគ្នានេះដែរ *Jelisic* បានយល់ព្រមតាមនិយមន័យថា "ជនស៊ីវិល" គឺជាពាក្យផ្ទុយនឹងពាក្យគោលដៅយោធា ដោយបានសម្រេចថា "សញ្ញាណនៃប្រជាជនស៊ីវិលដូចបានប្រើប្រាស់នៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈរួមបញ្ចូលជនទាំងអស់ដែលបានចាត់ទុកជាអ្នកបោះបង់ការប្រយុទ្ធនៅពេលឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើងក្រៅពីជនស៊ីវិលនៅក្នុងនិយមន័យតឹងរ៉ឹង"[24]។

17. រឿងក្តីនៅតាមសាលាក្តីនាពេលមុនៗក៏បានកត់សម្គាល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចធ្វើឡើងសំដៅប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៅពេលពួកគេពុំមែនជាគោលដៅស្របច្បាប់ (ពោលគឺ អ្នកប្រយុទ្ធនៅក្នុងការប្រទូស្តរ៉ាយ)។ ឧទាហរណ៍ អង្គជំនុំជម្រះក្នុងរឿងក្តី *Tadic* បានរំលឹកឡើងថា "លទ្ធភាពនៃការចាត់ទុកសមាជិកនៃកងកម្លាំងប្រដាប់អាវុធជាអ្នកដែលអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានទទួលស្គាល់តាំងពីឆ្នាំ១៩៤៦ មកម្លេះ"[25]។ នៅក្នុងរឿងក្តី *Kupreskic* អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា អ្នកប្រយុទ្ធមិនគួរដកចេញដោយសារឋានៈរបស់ពួកគេនោះទេ (ពោលគឺ អ្នកដែលបានស្លៀកឯកសណ្ឋាន) ដោយសារពួកគេក៏អាចត្រូវបានគេធ្វើទុក្ខបុកម្នេញផងដែរ ហើយ "ជនស៊ីវិល" ត្រូវតែបកស្រាយទៅតាមនោះ[26]។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្តី *Blaskic* អង្គជំនុំជម្រះសាលាដំបូងច្រានចោល

---

[21] ដូចខាងលើ។

[22] *រឿងក្តី* *Tadic* IT-94-1-T *សាលក្រម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៧ កថាខណ្ឌ ៦៣៧-៦៣៩*។

[23] *ដូចខាងលើ កថាខណ្ឌ ៦៣៩*។

[24] *រឿងក្តី* *Jelisic* IT-9510-T *សាលក្រម ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៥*។

[25] *រឿងក្តី* *Tadic* *កថាខណ្ឌ ៦៤០*។

[26] *រឿងក្តី* *Kupreskic* IT-95-16-T *សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៤៧*។

ទស្សនៈដែលថា សមាជិកកងទ័ពមិនបញ្ចូល "ប្រជាជនស៊ីវិល" យោងតាមសកម្មភាពជាក់ស្តែង[27]។ អង្គជំនុំជម្រះនេះបានសម្រេចថា "ប្រជាជនស៊ីវិល" រួមបញ្ចូល៖

> អតីតអ្នកប្រយុទ្ធ...ដែលលែងចូលរួមនៅក្នុងការប្រទូស្តរ៉ាយទៀតហើយនៅពេលឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយសារពួកគេបានចាកចេញពីជួរកងទ័ព ឬ លែងកាន់អាវុធទៀតហើយ ឬ ត្រូវបានដាក់ឲ្យជាអ្នកបោះបង់ការប្រយុទ្ធនៅទីបំផុត ជាពិសេសដោយសាររបួសរបស់ពួកគេ ឬ ដោយសារពួកគេត្រូវបានឃុំឃាំង។ វាក៏អាចដែរថា **ស្ថានភាពជាក់លាក់នៃជនរងគ្រោះនៅក្នុងពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងជាជាងឋានៈរបស់ជនរងគ្រោះរូបនោះ**ត្រូវយកមកពិចារណានៅក្នុងការកំណត់ឋានៈរបស់ពួកគេក្នុងនាមជាជនស៊ីវិល[28]។

ការយល់បែបនេះឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីការបែកចេញជារួមលើគោលការណ៍នៃការបែងចែក។ ការការពារពីការវាយប្រហារជាលក្ខណៈទូទៅ ឬ ជាលក្ខណៈប្រព័ន្ធគឺការពារទាំងឈ្លើយសឹក អតីតអ្នកប្រយុទ្ធ សមាជិកកងទ័ពរបស់ប្រទេសខ្លួនផ្ទាល់ និងសមាជិកនៃកងកម្លាំងប្រដាប់អាវុធនៅក្នុងអំឡុងពេលសន្តិភាពផងដែរ។

**ឃ. សាលាក្តី ICTY បានងាកចេញពីវិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់" ដោយគ្មានយុត្តិកម្មខ**

18. នៅក្នុងរឿងក្តី *Blaskic* និង *Martic* អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY បានងាកចេញដោយមិនទំនងពីវិធីសាស្ត្រដែលត្រូវបានបង្កើតឡើងនេះ។ អង្គជំនុំជម្រះបានចម្លងនិយមន័យនៃពាក្យ "ជនស៊ីវិល" ចេញពីមាត្រា ៥០ នៃពិធីសារបន្ថែមទីមួយដែលមិនរួមបញ្ចូលសមាជិកនៃកងកម្លាំងប្រដាប់អាវុធនោះឡើយ[29]។ ទោះបីជាយ៉ាងនេះក្តី មាត្រា ៥០ ឲ្យនិយមន័យនៃពាក្យ "ប្រជាជនស៊ីវិល" ដើម្បីគោលបំណងនៃការផ្តល់នូវការការពារក្រោមច្បាប់មនុស្សធម៌អន្តរជាតិមួយចំនួនជូនចំពោះសហគមន៍ដែលមានទំនាក់ទំនងជាមួយនឹងគូបដិបក្ខនៅក្នុងជម្លោះ។ វាពុំសមស្របក្នុងការយកនិយមន័យនេះមកបញ្ចូលក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ និយមន័យនៅក្នុងមាត្រា ៥០ នៃពាក្យ "ជនស៊ីវិល" មានន័យគ្រប់គ្រាន់នៅក្នុងក្របខណ្ឌគតិយុត្តនៃអនុសញ្ញាទីក្រុងហ្សឺណែវដែលផ្តល់នូវការការពារលម្អិត និងដោយឡែកចំពោះឈ្លើយសឹក និងចំពោះ

---

[27] *រឿងក្តី* Blaskic IT-95-14-T *សាលក្រម ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ២០៨*។

[28] *ដូចខាងលើ ត្រង់ កថាខណ្ឌ ២១៤*។

[29] *រឿងក្តី* Blaskic IT-95-14-A *សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១១០-១១៣*។ *រឿងក្តី* Martic IT-95-11-A *សាលដីកា ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ កថាខណ្ឌ ២៩០-៣០២*។

អ្នកប្រយុទ្ធដែលមានរបួស និងដែលមានជំងឺ។ ផ្ទុយមកវិញ "ជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សធម៌ត្រូវបានអនុវត្តជាច្រើនទសវត្សរ៍រួចមកហើយ ហើយសំអាងលើការបែងចែកសាមញ្ញជាងនេះរវាងជនដែលបានចូលរួមនៅក្នុងការប្រទូស្តរ៉ាយ និងជនដែលមិនបានចូលរួម។ មានហេតុផលសមស្របក្នុងការមិនដាក់បញ្ចូលសកម្មភាពស្របច្បាប់មួយចំនួននៅក្នុងសមរភូមិ ប៉ុន្តែមិនមានហេតុផលសមស្របក្នុងការមិនដាក់បញ្ចូលបុគ្គលិកយោធាទាំងអស់នៅក្នុងបរិបទផ្សេងទៀត។

19. អង្គជំនុំជម្រះតុលាការកំពូលបានសំអាងលើគោលការណ៍នៃការបែងចែកដើម្បីផ្តល់យុត្តិកម្មលើសេចក្តីសន្និដ្ឋានរបស់ខ្លួន[30]។ ទោះបីជាយ៉ាងនេះក៏ដោយ គោលការណ៍នោះគាំទ្រនូវការសន្និដ្ឋានមួយផ្ទុយពីនេះ។ ឧទាហរណ៍ ក្រោមគោលការណ៍នេះ ការកំណត់គោលដៅដោយចេតនាលើឈ្លើយសឹកត្រូវបានហាមឃាត់។ នៅក្នុងការវាយតម្លៃក្នុងលក្ខណៈសមមាត្រលើការវាយប្រហារ ការបង្កព្យសនកម្មដល់ឈ្លើយសឹកនឹងត្រូវដាក់បញ្ចូលជារបួសដល់ "ជនស៊ីវិល" មិនមែនដើម្បីជាប្រយោជន៍ផ្នែកយោធានោះទេ។

20. នៅក្នុងរឿងក្តី *Blaskic* អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ទឡ្ហីករណ៍ថា "ប្រសិនបើ [ជនរងគ្រោះ] ពិតជាសមាជិកនៃអង្គការប្រដាប់អាវុធមួយមែន ករណីដែលថាជននេះមិនមានបំពាក់អាវុធ ឬ ស្ថិតនៅក្នុងការវាយប្រយុទ្ធនៅក្នុងពេលប្រព្រឹត្តឧក្រិដ្ឋកម្មមិនបានផ្តល់ឱ្យជននេះនូវឋានៈជាជនស៊ីវិលឡើយ"[31]។ ការលើកឡើងបែបនេះត្រឹមត្រូវនៅក្នុងបរិបទមួយផ្សេង ពោលគឺ ភាគីនៃជម្លោះអាចវាយប្រហារសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់គូសត្រូវបានទោះបីជានៅពេលដែលពួកគេមិនកំពុងវាយប្រយុទ្ធនៅពេលនោះក៏ដោយ។ ទោះបីជាយ៉ាងនេះក្តី ទឡ្ហីករណ៍នេះមិនជាប់ពាក់ព័ន្ធនឹងការវាយប្រហារលើជនដែលបោះបង់ចោលការប្រយុទ្ធ ឈ្លើយសឹក សមាជិកនៃកងកម្លាំងរបស់ខ្លួន ឬ ការវាយប្រហារលើបុគ្គលិកយោធាក្នុងអំឡុងពេលសន្តិភាពនោះទាល់តែសោះ។

21. Werle និង Jessberger ក្រោយពីបានពិនិត្យមើលវិធីសាស្ត្រដែលត្រូវបានបង្កើតឡើងនៅក្នុងយុត្តិសាស្ត្រសាមញ្ញៗបំផុត បានសង្កេតឃើញថា "នៅក្នុងរឿងក្តី *Blaskic* អង្គជំនុំជម្រះតុលាការកំពូលបានងាកចេញពីគោលការណ៍ទាំងនេះ"។ អ្នកទាំងពីរកត់សម្គាល់ថា "ការផ្ទេរដោយមិនបានពិចារណា" នៃនិយមន័យក្នុងមាត្រា ៥០ នៃពិធីសារបន្ថែមទីមួយ "ខកខានមិនបានទទួលស្គាល់កម្មវត្ថុ និងគោលបំណង" នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ហេតុដូច្នេះ ត្រូវច្រានចោល"[32]។

---

[30] *រឿងក្តី* *Martic* លេខយោងជើងទំព័រ ៨០១។

[31] *រឿងក្តី* *Blaskic* *កថាខណ្ឌ ១១៥*។

[32] *Werle & Jessberger* *ទំព័រ ៣៣៦*។

01298913



ឧទាហរណ៍ "សមាជិកបច្ចុប្បន្ន និងអតីតសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនដែលពុំទទួលបានការការពារក្រោមច្បាប់មនុស្សធម៌អន្តរជាតិអាចក្លាយជាកម្មវត្ថុដោយផ្ទាល់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[33]។ ស្រដៀងគ្នានេះដែរ Cryer, Friman, Robinson និង Wilmshurst បានសិក្សាបញ្ហានានាជាមួយនឹងការផ្ទេរដោយហេតុផលតិចតួចពីមាត្រា ៥០ ហើយជម្រុញថា "គេសង្ឃឹមថា យុត្តាធិការផ្សេងទៀត...នឹងពិនិត្យមើលឲ្យបានហ្មត់ចត់លើហេតុផលរបស់សាលាក្តីនៅមុនពេលដើរតាមផ្លូវតែមួយ"[34]។ ករណីបច្ចុប្បន្នទាំងនេះចាំបាច់ឲ្យមានការពិនិត្យឲ្យបានហ្មត់ចត់ដូច្នេះ[35]។

## ខ. សន្និដ្ឋានលើការសង្កេត

22. ជំហររបស់អ្នកមិនមែនជាភាគីនៃរឿងក្តីស្របតាមគោលការណ៍នៃការបកស្រាយ រួមទាំង ការបកស្រាយក្នុងន័យតឹងរ៉ឹងផងដែរ។ យើងឃើញមាន "ន័យសាមញ្ញ" ចំនួនពីររួមគ្នាលើពាក្យ "ជនស៊ីវិល"៖ (១) ជាពាក្យផ្ទុយនឹងពាក្យអ្នកប្រយុទ្ធ (ដែលអាចត្រូវបានវាយប្រហារ) និង (២) ជនដែលមិនបានបម្រើនៅក្នុងកងកម្លាំងប្រដាប់អាវុធ។ ន័យទាំងពីរត្រូវបានលើកឡើងនៅក្នុងយុត្តិសាស្ត្រ។ គោលការណ៍នៃការបកស្រាយក្នុងន័យតឹងរ៉ឹងជាប់ទាក់ទងតែក្នុងពេលដែលវិធាននៃការបកស្រាយផ្សេងទៀតត្រូវបានប្រើប្រាស់អស់ហើយ។ ហេតុលផលរឹងមាំរារាំងការបកស្រាយក្នុងន័យចង្អៀតជាងនេះ។ ការបកស្រាយក្នុងន័យចង្អៀតជាងនេះផ្ទុយនឹងយុត្តិសាស្ត្រទូទៅ ហើយនឹងផ្ទុយនឹងហេតុផលនៃការរឹតត្បិតលើ "ជនស៊ីវិល"។ វាក៏អាចនឹងបង្កបញ្ហាឲ្យមានផលប៉ះពាល់ផងដែរ។ វានឹងមានន័យថា ការធ្វើទារុណកម្ម និងការកាប់សម្លាប់ជាលក្ខណៈប្រព័ន្ធលើឈ្លើយសឹករាប់ពាន់នាក់នឹងមិនអាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាននោះទេ។ វានឹងមានន័យថា ជនណាក៏ដោយអាចសម្លាប់សមាជិកនៃកងទ័ពរបស់ខ្លួនក្នុងលក្ខណៈទូទៅ និងក្នុងលក្ខណៈជាប្រព័ន្ធ ហើយការធ្វើ

---

[33] *ដូចខាងលើ ទំព័រ ៣៣៧*។

[34] Cryer *និងអ្នកផ្សេងទៀត ទំព័រ ២៤២*។

[35] *នៅក្នុងរឿងក្តី Berma អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានគាំទ្ររឿងក្តី Blaskic និងរឿងក្តី Martic ប៉ុន្តែបញ្ហាដែលពិភាក្សានៅទីនេះពុំបានលេចឡើងនៅក្នុងរឿងក្តីនោះទេ ហើយពុំត្រូវបានពិនិត្យមើលឲ្យហ្មត់ចត់ផងដែរ។ សេចក្តីសម្រេចដែលបានលើកឡើងទាក់ទងនឹង "កត្តានានា" ដែលពិតជាស្របជាមួយនឹងទស្សនៈ "ផ្តោតលើគោលដៅស្របច្បាប់"។ អ្វីដែលគួរឲ្យសរសើរនោះ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមថា "នៅពេលពិចារណាលើគោលបំណងនៃមាត្រា ៧ អង្គជំនុំជម្រះយល់ឃើញថា សញ្ញាណនេះត្រូវបកស្រាយក្នុងលក្ខណៈមួយដែលពុំដកចេញជនផ្សេងទៀតដែលត្រូវបានការពារ"។ ចំណុចនេះលេចចេញនៅពេលពិភាក្សាអំពីជនរងគ្រោះនៃឧក្រិដ្ឋកម្មបែបនេះ ប៉ុន្តែការពិចារណាដូចគ្នាអនុវត្តចំពោះវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ រឿងក្តី Bemba* ICC Doc. ICC-01/05-01/08-3343 *ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ១៥២-៥៦*។

ដូច្នេះនឹងមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម ឬ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ ជនទាំងឡាយមិនបាត់បង់ការការពារចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេតាមរយៈការកាន់កាប់របស់ពួកគេ។ វិធីសាស្ត្រ "ផ្អែកលើគោលដៅស្របច្បាប់" ផ្ទុះបញ្ឆាំងស្ថានភាពពិតប្រាកដរបស់ជនណាម្នាក់ក្នុងបរិបទនៃឧក្រិដ្ឋកម្ម។

23. ទម្លឹករណ៍នៅក្នុងនេះអនុវត្តលើរយៈកាលឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ដោយហេតុអ្នកមិនមែនជាភាគីនៃរឿងក្តីសន្និដ្ឋានថា "ប្រជាជនស៊ីវិល" នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតែងតែត្រូវបានផ្អែកលើគោលការណ៍នៃការបែងចែក។ អ្នកមិនមែនជាភាគីនៃរឿងក្តីសូមជំរុញឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមយុត្តិសាស្ត្រដើម ហើយនឹងហេតុផលសំខាន់នៃការកំហិតលើ "ជនស៊ីវិល" ពោលគឺការដកចេញការវាយប្រហារស្របច្បាប់លើគោលដៅស្របច្បាប់។

ធ្វើនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦

*ហត្ថលេខា*

Darryl Robinson